# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៥៣ អនក្រ.បក

ក្រសួងសុខាភិបាល
ចូលមក កាវិ.សៀវភៅ
ថ្ងៃទី 12 ខែ 6 ឆ្នាំ200... ម៉ោង 7 នាទី
លេខ 1137 រ.ប

## អនុក្រឹត្យ

## ស្តីពីការទទួលស្គាល់សមាសភាព

## ការិយាល័យរបស់ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិកម្ពុជា

## សម្រាប់អាណត្តិ ២ ឆ្នាំ លើកទី៣

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០០/០៣៩ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈគ្រូពេទ្យ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិកម្ពុជា

### សម្រេច

មាត្រា ១ : ត្រូវបានទទួលស្គាល់សមាសភាពការិយាល័យក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិកម្ពុជា ចំនួន ០៧ រូប ដែលបានជ្រើសរើសដោយបោះឆ្នោត សំរាប់អាណត្តិ ២ ឆ្នាំ លើកទី៣ កាលពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៧ សំរាប់ដឹកនាំ និងគ្រប់គ្រង ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តមសាស្ត្រាចារ្យវេជ្ជបណ្ឌិត លី ម៉ូរ ប្រធាន

២-លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត ធា គ្រួយ អនុប្រធានទី១

៣- លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត យត់ សុផាន់ណា អនុប្រធានទី២

៤-ឯកឧត្តមគ្រូពេទ្យ ហ៊ុយ សេដ្ឋ អគ្គលេខាធិការ

៥-លោកវេជ្ជបណ្ឌិត ជា ប៊ុនហេង អគ្គលេខាធិការរង

៦- លោកវេជ្ជបណ្ឌិត ស បញ្ញា ហេរញ្ញិក

៧- លោកវេជ្ជបណ្ឌិត សួន ចាន់ធី ហេរញ្ញិករង

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ប្រធានក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិកម្ពុជា អភិបាលខេត្ត ក្រុងដែលពាក់ព័ន្ធ និងសមាសភាពដែលមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មិនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ